អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃនេះ អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីពិចារណារបស់ខ្លួន ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤/២។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយរបស់ខ្លួន ក្នុងសំណុំរឿង ០០៤/២ ហើយនៅក្នុងដីកាដាច់ដោយឡែកមួយ គាត់បានសម្រេចទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលនៅសេសសល់ អនុលោមតាមវិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង។

បន្ទាប់ពីការចេញសេចក្តីពិចារណារបស់អង្គជំនុំជម្រះ ទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/២ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ មក អង្គបុរេជំនុំជម្រះបានពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍ពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក្យសុំរបស់ពួកគេត្រូវបានបដិសេធដោយដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

ចាប់តាំងពីពេលចាប់ផ្តើមដំណើរការស៊ើបអង្កេតមក មានប្រជាពលរដ្ឋចំនួន ១.៩២០ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤/២ (កថាខណ្ឌ ៣)។

នៅក្នុងសេចក្តីពិចារណារបស់ខ្លួន អង្គបុរេជំនុំជម្រះបានបញ្ជាក់បំភ្លឺជាឯកច្ឆ័ន្ទទៅលើគោលការណ៍គតិយុត្តិ ដែលគ្រប់គ្រងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអ.វ.ត.ក (កថាខណ្ឌ៣១-៣៨)។

ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនពីចៅក្រមចំនួន ៤ រូបយ៉ាងតិច ដើម្បីសម្រេចទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ នៅក្នុងសំណុំរឿងនេះបានទេ។

ចៅក្រមជាតិបានសន្និដ្ឋានថា រាល់ពាក្យសុំទាំងអស់ក្នុងសំណុំរឿង ០០៤/២ មិនអាចទទួលយកបានទេ ហើយត្រូវបដិសេធចោល ដោយសារនៅក្នុងសេចក្តីពិចារណាចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ចៅក្រមជាតិ "បានសម្រេចបញ្ជាក់ទៅលើដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំងនឹង អោ អាន និងច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ

ដែលបានចេញប្រឆាំងនឹង អោ អាន” (កថាខណ្ឌ ៤១-៤៣)។

ចៅក្រមអន្តរជាតិបានពិចារណាឃើញថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន ហើយបានពិនិត្យទៅលើអង្គសេចក្តីនៃពាក្យសុំទាំងអស់។ ជាសរុបមក ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសនៅក្នុងការចេញដីកាសម្រេចរបស់ខ្លួន ដូចបានលើកឡើងនៅក្នុងមូលដ្ឋានទី២ និងទី៤ ហើយថាជនរងគ្រោះចំនួន ១២ នាក់បន្ថែមទៀត គួរត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ (កថាខណ្ឌ ១១៧)។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះអាចរកបាននៅលើគេហទំព័រ៖
https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D362_6_KH.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.phektra@eccc.gov.kh